ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ...១៤...ស.ស.រ...

# សេចក្តីសំរេច
## ស្តីពី
## ការកែសំរួលប្រការ១ និងប្រការ២ នៃសេចក្តីសំរេច
## ស្តីពី
## ការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងជីវៈចំរុះ

---

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន

-បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ-បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន

-បានឃើញសេចក្តីសំរេចលេខ ១៦ សសរ ចុះថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០០១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងជីវៈចំរុះ

-បានឃើញសេចក្តីប្រកាសលេខ ០១ ប្រក ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីវិធានការគ្រប់គ្រង និងលប់បំបាត់ភាពអនាធិបតេយ្យក្នុងវិស័យព្រៃឈើរបស់រាជរដ្ឋាភិបាល

-បានឃើញសេចក្តីប្រកាសលេខ ០៦ ប្រក ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ១៩៩៩ ស្តីពីវិធានការលប់បំបាត់ភាពអនាធិបតេយ្យ ក្នុងបញ្ហាទន្ទ្រានកាន់កាប់ដីធ្លីរបស់រាជរដ្ឋាភិបាល

-យោងភាពចាំបាច់របស់រាជរដ្ឋាភិបាល ក្នុងការប្រើប្រាស់ ការការពារ និងការគ្រប់គ្រងជីវៈចំរុះ សំរាប់អភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពបរិស្ថាននៅកម្ពុជា ។

## សំរេច

**ប្រការ ១ :** កែសំរួលប្រការ ១ នៃសេចក្តីសំរេចលេខ ១៦ សសរ ចុះថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០០១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងជីវៈចំរុះ ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១-ឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន | | ប្រធាន |
| ២-ឯកឧត្តមរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | មួយរូប | អនុប្រធាន |
| ៣-ឯកឧត្តមអនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | មួយរូប | សមាជិក |
| ៤-ឯកឧត្តមអនុរដ្ឋលេខាធិការក្រសួងផែនការ | មួយរូប | សមាជិក |
| ៥-ឯកឧត្តមអនុរដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | មួយរូប | សមាជិក |
| ៦-ឯកឧត្តមអនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | មួយរូប | សមាជិក |
| ៧-ឯកឧត្តមអនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | មួយរូប | សមាជិក |
| ៨-ឯកឧត្តមអនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | មួយរូប | សមាជិក |
| ៩-ឯកឧត្តមអនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | មួយរូប | សមាជិក |
| ១០-ឯកឧត្តមអគ្គលេខាធិការ គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា | មួយរូប | សមាជិក |
| ១១-ឯកឧត្តមអគ្គលេខាធិការរង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | មួយរូប | សមាជិក |
| ១២-ឯកឧត្តមអនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | មួយរូប | សមាជិក |
| ១៣-ឯកឧត្តមអនុរដ្ឋលេខាធិការក្រសួងសុខាភិបាល | មួយរូប | សមាជិក |
| ១៤-ឯកឧត្តមអនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | មួយរូប | សមាជិក |
| ១៥-តំណាងអភិបាលខេត្ត-ក្រុងដែលពាក់ព័ន្ធ | | សមាជិក |

**ប្រការ ២ :** កែសំរួលតួនាទី និងភារកិច្ចប្រការ ២ នៃសេចក្តីសំរេចលេខ ១៦ សសរ ចុះថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០០១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងជីវៈចំរុះដូចតទៅ :

-លើកសំណើគោលនយោបាយ ស្តីពីជីវៈចំរុះជូនរាជរដ្ឋាភិបាលពិនិត្យ និងសំរេច

-ធ្វើទំនាក់ទំនងជាផ្លូវការរវាងរាជរដ្ឋាភិបាលកម្ពុជា និងលេខាធិការដ្ឋាន នៃអនុសញ្ញាស្តីពីជីវៈចំរុះ និងគាំទ្រនូវតួនាទី និងភារកិច្ចរបស់លេខាធិការដ្ឋាន នៃអនុសញ្ញាស្តីពីជីវៈចំរុះ

-ជ្រើសរើស ឬចាត់តាំងតំណាងប្រទេសកម្ពុជា ដើម្បីចូលរួមនៅក្នុងសិក្ខាសាលាជីវៈចំរុះ និងសម័យប្រជុំនានារបស់អនុសញ្ញាស្តីពីជីវៈចំរុះ

-ជំរុញ និងគាំទ្រដល់ការផ្សព្វផ្សាយអនុសញ្ញាស្តីពីជីវៈចំរុះនៅក្នុងប្រទេស

-ផ្តល់យោបល់ជូនរាជរដ្ឋាភិបាល ស្តីពីអនុសញ្ញា និងសេចក្តីព្រាងអនុស្សរណៈនានា ដែលទាក់ទងទៅនឹងការអនុវត្តអនុសញ្ញាស្តីពីជីវៈចំរុះ

-ត្រួតពិនិត្យ និងជំរុញលើកិច្ចសហប្រតិបត្តិការរវាងស្ថាប័នពាក់ព័ន្ធ លើបញ្ហាជីវៈចំរុះ

-ត្រួតពិនិត្យ និងសំរេចលើការបង្កើតយុទ្ធសាស្ត្រ និងផែនការសកម្មភាពជីវៈចំរុះ

-ជំរុញការអនុវត្ត ត្រួតពិនិត្យ និងវាយតំលៃលើយុទ្ធសាស្ត្រ និងផែនការសកម្មភាពជីវៈចំរុះ

-កំណត់អោយបានច្បាស់ថា យុទ្ធសាស្ត្រ និងផែនការសកម្មភាពជីវៈចំរុះ ត្រូវបានបញ្ចូលទៅក្នុងផែនការសកម្មភាពរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច ៥ ឆ្នាំ របស់កម្ពុជា

-ត្រួតពិនិត្យ និងជំរុញនូវការបង្កើតគោលនយោបាយ ស្តីពីជីវៈចំរុះរបស់ក្រសួង និងស្ថាប័នពាក់ព័ន្ធ

-ពិនិត្យឡើងវិញលើភាពចាំបាច់ជាអាទិភាពនៃយុទ្ធសាស្ត្រ និងផែនការសកម្មភាពជីវៈចំរុះរៀងរាល់ពីរឆ្នាំម្តង ដោយបញ្ចូលនូវសកម្មភាពផ្សេងៗ សំរាប់ការប្រើប្រាស់ ការការពារ និងការគ្រប់គ្រងជីវៈចំរុះប្រកបដោយនិរន្តរភាពបរិស្ថាននៅកម្ពុជា

-ត្រួតពិនិត្យនិងកំណត់អោយបានច្បាស់ថារាល់លក្ខខ័ណ្ឌរបស់អ្នកផ្តល់ជំនួយសំរាប់គំរោង ដែលពាក់ព័ន្ធទៅនឹងជីវៈចំរុះ ត្រូវស្ថិតនៅក្នុងក្របខ័ណ្ឌនៃយុទ្ធសាស្ត្រ និងផែនការសកម្មភាពជីវៈចំរុះ

-តាមដានការអនុវត្តនៃយុទ្ធសាស្ត្រ និងផែនការសកម្មភាពជីវៈចំរុះ និងបញ្ហាជីវៈចំរុះផ្សេងៗ

-ធ្វើសេចក្តីរាយការណ៍ជូនរាជរដ្ឋាភិបាល ហើយចំលងជូនគណៈកម្មាធិការសិទ្ធិមនុស្ស ស្តីពីការអនុវត្តនៃយុទ្ធសាស្ត្រ និងផែនការសកម្មភាពជីវៈចំរុះ និងបញ្ហាជីវៈចំរុះដទៃទៀត ។

-ឃ្លាំមើល និងវាយតំលៃការបំពេញកាតព្វកិច្ច និងពិធីសារកាតាហ្សេណា ស្តីពីជីវសុវត្ថិភាព

-ជំរុញអោយមានការយល់ដឹងជាសាធារណៈនូវតំរូវការក្នុងការរៀបចំក្របខ័ណ្ឌជីវសុវត្ថិភាពជាតិអោយបានឆាប់

-កែសំរួល អនុម័ត និងវាយតំលៃការរៀបចំក្របខ័ណ្ឌជីវសុវត្ថិភាពជាតិ និងធានាការអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់

-ផ្តល់ការណែនាំពីគោលនយោបាយទូទៅ ស្តីពីការអនុវត្តគំរោងជាតិ

-វាយតំលៃ និងណែនាំអំពីលទ្ធផលសំខាន់ៗ របស់គំរោងជាតិ

-ផ្តល់ឱ្យមានការសំរបសំរួល និងការធ្វើសំរេចដោយប្រសិទ្ធភាព រវាងគំរោងជាតិ និងស្ថាប័នពាក់ព័ន្ធសំខាន់ៗ ដទៃទៀត

-ធានាក្របខ័ណ្ឌជីវសុវត្ថិភាពជាតិស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលផ្នែកបរិស្ថាន ។

**ប្រការ ៣ :** ប្រការដទៃទៀតនៃសេចក្តីសំរេចលេខ ១៦ សសរ ចុះថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០០១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងជីវៈចំរុះ ត្រូវរក្សាទុកជាធរមានដដែល ។

**ប្រការ ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គលេខាធិការនៃគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ អភិបាលខេត្ត-ក្រុង ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

-ក្រសួង ព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចប្រការ ៤

-ឯកសារ-កាលប្បវត្តិ .